# សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# រដ្ឋាភិបាលឌីជីថល

# នៃព្រះរាជាណាចក្រកម្ពុជា

DRAFT

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........ ១**

*មាត្រា ១ ._ គោលបំណង ........ ១*

*មាត្រា២ ._ វិសាលភាព ........ ១*

*មាត្រា៣ ._ និយមន័យ ........ ១*

**ជំពូកទី២ ស្ថាប័នមានសមត្ថកិច្ច ........ ១**

*មាត្រា៤ ._ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ........ ១*

*មាត្រា៥ ._ អង្គភាពបរិវត្តកម្មឌីជីថល ........ ១*

**ជំពូកទី៣ គោលការណ៍ទូទៅ ........ ២**

*មាត្រា៦ ._ គោលការណ៍ទូទៅ ........ ២*

**ជំពូកទី៤ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ........ ២**

*មាត្រា៧ ._ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ........ ២*

*មាត្រា៨ ._ ហេដ្ឋារចនាសម្ព័ន្ធឌីជីថលសំខាន់ៗ ........ ២*

*មាត្រា៩ ._ បណ្តាញដោយឡែករដ្ឋាភិបាល ........ ៣*

*មាត្រា១០ ._ មជ្ឈមណ្ឌលទិន្នន័យនិងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាល ........ ៣*

***មាត្រា១១** ._ ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល ........ ៤*

*មាត្រា១២ ._ និហិតដ្ឋានទិន្នន័យជាតិ ........ ៤*

*មាត្រា១៣ ._ ថ្នាលផ្លាស់ប្តូរទិន្នន័យធំ ........ ៥*

***មាត្រា១៤** ._ ហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់ ........ ៥*

**ជំពូកទី៥ សេវាឌីជីថល ........ ៥**

*មាត្រា១៥ ._ សេវាឌីជីថល ........ ៥*

*មាត្រា១៦ ._ ថ្នាលសេវារួមរដ្ឋាភិបាល ........ ៥*

*មាត្រា១៧ ._ ការផ្តល់និងការទទួលបានសេវាឌីជីថល ........ ៦*

*មាត្រា១៨ ._ ក្របខណ្ឌអន្តរប្រតិបត្តិការរដ្ឋាភិបាលឌីជីថលកម្ពុជា ........ ៦*

*មាត្រា១៩ ._ ការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថល ........ ៦*

*មាត្រា២០ ._ ឈ្មោះដែនរដ្ឋាភិបាល ........ ៦*

*មាត្រា២១ ._ វេបសាយ និងអ៊ីម៉ែលរដ្ឋាភិបាល ........ ៧*

*មាត្រា២២ ._ គណនីបណ្តាញសង្គមក្រសួង ស្ថាប័ន ........ ៧*

*មាត្រា២៣ ._ ដំណើរឆ្ពោះទៅការកាត់បន្ថយការប្រើប្រាស់ក្រដាស ........ ៧*

*មាត្រា២៤ ._ ការចូលរួមរបស់ប្រជាពលរដ្ឋតាមប្រព័ន្ធឌីជីថល ........ ៨*

**ជំពូកទី៦ អភិបាលកិច្ចទិន្នន័យ ........ ៨**

DRAFT

*មាត្រា២៥ ._ អភិបាលកិច្ចទិន្នន័យ ........ ៨*
*មាត្រា២៦ ._ ការប្រមូល រក្សាទុក ផលិតឡើងវិញ ផ្លាស់ប្តូរ ចែកចាយ ឬប្រើប្រាស់ទិន្នន័យ ........ ៨*
*មាត្រា២៧ ._ សមាហរណកម្មប្រព័ន្ធអេឡិចត្រូនិក ........ ៨*
*មាត្រា២៨ ._ ការចែករំលែកទិន្នន័យ ........ ១០*
*មាត្រា២៩ ._ ការអោក់សេសទិន្នន័យ ........ ១០*
*មាត្រា៣០ ._ ទិន្នន័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ ១០*

**ជំពូកទី៧ គម្រោង ថវិកា និងមូលនិធិរដ្ឋាភិបាលឌីជីថល ........ ១១**

*មាត្រា៣១ ._ គម្រោងរដ្ឋាភិបាលឌីជីថល ........ ១១*
*មាត្រា៣២ ._ មូលនិធិរដ្ឋាភិបាលឌីជីថល ........ ១១*

**ជំពូកទី៨ កិច្ចសហប្រតិបត្តិការ និងសន្ទស្សន៍នៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ........ ១១**

*មាត្រា៣៣ ._ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍និងវិស័យឯកជន ........ ១១*
*មាត្រា៣៤ ._ សន្ទស្សន៍នៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ........ ១១*
*មាត្រា៣៥ ._ ទិវារដ្ឋាភិបាលឌីជីថល ........ ១២*

**ជំពូកទី៩ ការអនុវត្ត ........ ១២**

*មាត្រា៣៦ ._ ........ ១២*

**ជំពូកទី១០ ទោសប្បញ្ញត្តិ ........ ១២**

*មាត្រា៣៧ ._ ទណ្ឌកម្ម ........ ១២*
*មាត្រា៣៨ ._ បទល្មើសនៃការមិនប្រើប្រាស់អ៊ីម៉ែលឬវេបសាយរដ្ឋាភិបាល ........ ១២*
*មាត្រា៣៩ ._ បទល្មើសបង្កើតគណនីបណ្តាញសង្គមក្រសួង ស្ថាប័នឬព័ត៌មានក្លែងក្លាយ ........ ១២*
*មាត្រា៤០ ._ បទល្មើសនៃការផលិតឡើងវិញទិន្នន័យដោយគ្មានការអនុញ្ញាត ........ ១២*
*មាត្រា៤១ ._ បទល្មើសមិនបង់ប្រាក់ដាកពិន័យ ........ ១២*
*មាត្រា៤២ ._ ការទទួលខុសត្រូវព្រហ្មទណ្ឌ ........ ១៣*

**ជំពូកទី១១ អន្តរប្បញ្ញត្តិ ........ ១៣**

*មាត្រា៤៣ ._ ........ ១៣*

**ជំពូកទី១២ អវសានប្បញ្ញត្តិ ........ ១៣**

*មាត្រា៤៤ ._ និរាករណ៍ ........ ១៣*
*មាត្រា៤៥ ._ ........ ១៣*

**ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថលនៃព្រះរាជាណាចក្រកម្ពុជា សទ្ទានុក្រម ........ ១៤**

DRAFT

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១ ._ គោលបំណង

ច្បាប់នេះកំណត់អំពីគោលការណ៍ វិធាន និងយន្តការកសាងរដ្ឋាភិបាលឌីជីថលតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្នុងគោលបំណងអភិវឌ្ឍសេវាឌីជីថល ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងអភិបាលកិច្ចទិន្នន័យ សម្រាប់រដ្ឋាភិបាលទាំងមូល ដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ។

### មាត្រា២ ._ វិសាលភាព

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងជនគ្រប់រូបនៅព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។

### មាត្រា៣ ._ និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

### មាត្រា៤ ._ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល

ត្រូវបានបង្កើតគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ដើម្បីធានានូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការបំពេញមុខងារជាសេនាធិការជូនក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល លើការងារបច្ចេកទេស និងគោលនយោបាយនៅក្នុងការដឹកនាំ សម្របសម្រួល និងជំរុញការកសាងរដ្ឋាភិបាលឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវដឹកនាំដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងមានសមាជិកជាតំណាងពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ គណៈកម្មាធិការរដ្ឋាភិបាលត្រូវឌីជីថលមានអគ្គលេខាធិការដ្ឋានជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា៥ ._ អង្គភាពបរិវត្តកម្មឌីជីថល

ក្រសួង ស្ថាប័នត្រូវបង្កើត អង្គភាពបរិវត្តកម្មឌីជីថល ជាអង្គភាពដែលស្ថិតក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។

អង្គភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង ស្ថាប័នត្រូវបង្កើតដោយអនុលោមតាមអនុក្រឹត្យស្តីពីគោលការណ៍នៃការរៀបចំអង្គភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង ស្ថាប័ន។

## ជំពូកទី៣
## គោលការណ៍ទូទៅ

### មាត្រា៦ ._ គោលការណ៍ទូទៅ

ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលនិងប្រជាជនត្រូវតែយល់ និងគោរពតាមគោលការណ៍ ដូចខាងក្រោម៖

ក-រដ្ឋាភិបាលឌីជីថលសំដៅដល់ដំណើរការនិងការអនុវត្តការងារនៃការផ្តល់សេវាឌីជីថល មិនមែនគ្រាន់តែរៀបចំឱ្យប្រព័ន្ធឌីជីថលទេ។

ខ-រដ្ឋាភិបាលឌីជីថលជំរុញការកសាងពលរដ្ឋឌីជីថលនិងប្រជាធិបតេយ្យឌីជីថល។

គ-សេវារដ្ឋាភិបាលឌីជីថលត្រូវអាចអាក់សេសបានគ្រប់គ្នា។

ឃ-រដ្ឋាភិបាលឌីជីថលគឺជាប្រព័ន្ធរដ្ឋាភិបាលមួយដែលបានធ្វើសមាហរណកម្មនៃប្រព័ន្ធជាច្រើន។

ង-រដ្ឋាភិបាលឌីជីថលត្រូវការសុសវែរដែលមានកូដបើកចំហ។

ច-រដ្ឋាភិបាលឌីជីថលត្រូវការកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នទាំងអស់ក្នុងអភិក្រម ជវភាពនៃប្រព័ន្ធតួអង្គតែមួយ។

## ជំពូកទី៤
## ហេដ្ឋារចនាសម្ព័ន្ធឌីជីថល

### មាត្រា៧ ._ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់ដំណើរការងាររបស់ក្រសួង ស្ថាប័ន និងការផ្តល់សេវាឌីជីថលរបស់រដ្ឋាភិបាល។ ហេដ្ឋារចនាសម្ព័ន្ធឌីជីថលត្រូវចាត់ទុកជាផ្នែកមួយនៃទ្រព្យសម្បត្តិរដ្ឋដែលត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

ហេដ្ឋារចនាសម្ព័ន្ធឌីជីថលអាចជាហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលជាកម្មសិទ្ធិរបស់រដ្ឋ និង/ឬហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលជាកម្មសិទ្ធិរបស់ឯកជន និងជួលប្រើប្រាស់ដោយក្រសួង ស្ថាប័ន។គោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា៨ ._ ហេដ្ឋារចនាសម្ព័ន្ធឌីជីថលសំខាន់ៗ

ហេដ្ឋារចនាសម្ព័ន្ធឌីជីថលសំខាន់ៗដែលកំណត់ដោយច្បាប់នេះ មានជាអាទិ៍៖

ក-បណ្តាញដោយឡែករដ្ឋាភិបាល (Government Private Network)។

ខ-មជ្ឈមណ្ឌលទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាល។

គ-ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល។

ឃ-និហិតដ្ឋានទិន្នន័យជាតិ។

ង-ថ្នាលផ្លាស់ប្តូរទិន្នន័យធំ។

ច-ហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់។

ឆ-ហេដ្ឋារចនាសម្ព័ន្ធឌីជីថលសំខាន់ៗដទៃទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។

## មាត្រា៩ ._ បណ្តាញដោយឡែករដ្ឋាភិបាល

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវគ្រប់គ្រងបណ្តាញដោយឡែករដ្ឋាភិបាល។ បណ្តាញដោយឡែករដ្ឋាភិបាលរួមមាន៖

ក- និហិតដ្ឋានទិន្នន័យជាតិ។

ខ- រាល់ការតភ្ជាប់នៃបណ្តាញរូបវន្ត បណ្តាញនិម្មិត ឬបណ្តាញក្លោដ ដែលប្រតិបត្តិការដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬ ក្រសួង ស្ថាប័នដែលទទួលបានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

គ- ថ្នាលសេវារួមរដ្ឋាភិបាល រួមទាំងហេដ្ឋារចនាសម្ព័ន្ធឌីជីថល អ៊ីនធឺណិត និងកម្មវិធីជាសេវា ដែលបង្កើនការតភ្ជាប់បណ្តាញ និងការចែករំលែកទិន្នន័យរវាងក្រសួង ស្ថាប័ន។

ក្រសួង ស្ថាប័នមិនត្រូវប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញផ្សេងទៀតពីបណ្តាញដោយឡែករដ្ឋាភិបាលបានឡើយ លើកលែងតែមានការអនុញ្ញាតពីគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល។

ក្នុងករណីដែលក្រសួង ស្ថាប័នមានបំណងប្រើហេដ្ឋារចនាសម្ព័ន្ធបណ្តាញផ្សេងទៀត ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរមកគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល។

## មាត្រា១០ ._ មជ្ឈមណ្ឌលទិន្នន័យនិងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាល

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវបង្កើតមជ្ឈមណ្ឌលទិន្នន័យនិងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាល ដើម្បីភ្ជាប់បណ្តាញដោយឡែករដ្ឋាភិបាលទៅនឹងសេវាឌីជីថលសម្រាប់ក្រសួង ស្ថាប័ន។ ការបង្កើតមជ្ឈមណ្ឌលទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាលត្រូវគិតគូរលើប្រសិទ្ធភាពនៃការគ្រប់គ្រង ការប្រើប្រាស់ធនធាន ការវិនិយោគ សន្តិសុខសាយប័រ និងធនធានមនុស្សសម្រាប់គ្រប់គ្រង ព្រមទាំងអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាលរួមមាន ហេដ្ឋារចនាសម្ព័ន្ធក្លោដជួលប្រើដោយរដ្ឋាភិបាល និងហេដ្ឋារចនាសម្ព័ន្ធក្លោដដោយឡែករបស់រដ្ឋាភិបាល។

ក្រសួង ស្ថាប័នដែលមានតម្រូវការប្រើប្រាស់ថ្នាលឌីជីថលច្រើននិងមានធនធានអាចរៀបចំហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាលដោយឡែក ប្រសិនបើចាំបាច់ និងត្រូវគោរពតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យនិងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាល។

ក្រសួង ស្ថាប័នដែលមានតម្រូវការប្រើប្រាស់ថ្នាលឌីជីថលនិងមានធនធានតិចតួចត្រូវប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យនិងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាលដែលបង្កើតដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬមជ្ឈមណ្ឌលទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាលរបស់ក្រសួង ស្ថាប័នដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល។ ក្នុងរយៈពេល១ (មួយ) ឆ្នាំគិតចាប់ពីថ្ងៃបង្កើតមជ្ឈមណ្ឌលទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាល ក្រសួង ស្ថាប័នដែលប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធក្លោដ ដែលមិនមែនជាហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាលត្រូវផ្លាស់ទៅ និងធ្វើប្រតិបត្តិការនៅលើហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាល។ ក្នុងករណីក្រសួង ស្ថាប័ននៅតែបន្តប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ

ក្លោងនោះ ក្រសួង ស្ថាប័នត្រូវស្នើសុំការអនុញ្ញាតជាផ្លូវការពីគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលក្នុងរយៈពេល៩០ (កៅសិប) ថ្ងៃគិតចាប់ពីថ្ងៃបង្កើតហេដ្ឋារចនាសម្ព័ន្ធក្លោងរដ្ឋាភិបាល។

គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យនិងហេដ្ឋារចនាសម្ព័ន្ធក្លោងរដ្ឋាភិបាលត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា១១ ._ ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល ដើម្បីផ្ទៀងផ្ទាត់បុគ្គលធ្វើប្រតិបត្តិការអនឡាញនៅព្រះរាជាណាចក្រកម្ពុជា។

ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថលត្រូវបង្កើតសម្រាប់អាក់សេសទៅសេវាឌីជីថល មានជាអាទិ៍ ការស្នើសុំសេវានិងបង់ថ្លៃសេវាសាធារណៈ សេវាសន្តិសុខសង្គម សេវាប្រៃសណីយ៍ជាតិ ការជាវសេវាទឹក សេវាអគ្គិសនី និងសេវាផ្សេងៗទៀតតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

បុគ្គលគ្រប់រូបអាចបង្កើតគណនីផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថលមួយ ដើម្បីប្រើប្រាស់សម្រាប់ធ្វើប្រតិបត្តិការអនឡាញនៅព្រះរាជាណាចក្រកម្ពុជា។ បុគ្គលដែលមានបំណង បង្កើតគណនីផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថលត្រូវមានភ្ជាប់នូវឯកសារណាមួយ ដូចខាងក្រោម៖

ក. រូបវន្តបុគ្គល សញ្ជាតិខ្មែរ៖

១.អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

២.លិខិតឆ្លងដែន។

៣.បណ្ណបើកបរ។

៤.ឯកសារអត្រានុកូលដ្ឋានបញ្ជាក់កំណើត។

៥.បណ្ណសមាជិកបេឡាជាតិរបបសន្តិសុខសង្គម។

ខ. រូបវន្តបុគ្គលបរទេស៖

១.លិខិតឆ្លងដែន។

គ. នីតិបុគ្គលបង្កើតឡើងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា៖

១.វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។

២.ឯកសារចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។

៣.ឯកសារបញ្ជាក់ការបង្កើតឬការចុះបញ្ជីផ្សេងទៀត ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ការរៀបចំ ការគ្រប់គ្រង និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល និងគណនីផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថលត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា១២ ._ និហិតដ្ឋានទិន្នន័យជាតិ

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវបង្កើតនិងគ្រប់គ្រងនិហិតដ្ឋានទិន្នន័យជាតិ ដែលមានប្រព័ន្ធសន្តិសុខខ្ពស់ដែលអនុលោមតាមស្តង់ដាអន្តរជាតិ ដើម្បីរក្សា និងបម្រុងទុកទិន្នន័យជាតិ ទិន្នន័យរដ្ឋាភិបាល និងទិន្នន័យក្រសួង ស្ថាប័ន។

ការបង្កើតនិងការគ្រប់គ្រងនិហិតដ្ឋានទិន្នន័យជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៣ ._ ថ្នាលផ្លាស់ប្តូរទិន្នន័យធំ**

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំថ្នាលផ្លាស់ប្តូរទិន្នន័យធំ ដែលជាថ្នាលឌីជីថលរដ្ឋាភិបាលមួយប្រើប្រាស់សម្រាប់ផ្លាស់ប្តូរទិន្នន័យជាកញ្ចប់ដែលមានទំហំធំ ឬទិន្នន័យធំ។

ការរៀបចំ ការគ្រប់គ្រង និងការប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យធំត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៤ ._ ហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់**

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំផែនការមេសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់ថ្នាក់ជាតិ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអន្តរប្រតិបត្តិការដែលមានវិសាលភាពទូលំទូលាយគ្របដណ្តប់លើការទូទាត់សងប្រាក់ឌីជីថលនៅក្នុងគ្រប់វិស័យ និងគ្រប់ទិដ្ឋភាព ដើម្បីធានាឱ្យមានភាពជឿជាក់និងទំនុកចិត្តនៃអន្តរប្រតិបត្តិការ ព្រមទាំងសុវត្ថិភាពនិងប្រសិទ្ធិភាពខ្ពស់នៃប្រព័ន្ធ។

ការរៀបចំ ការគ្រប់គ្រង និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់ថ្នាក់ជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## សេវាឌីជីថល

**មាត្រា១៥ ._ សេវាឌីជីថល**

ក្រសួង ស្ថាប័នត្រូវកំណត់អំពីប្រភេទសេវាឌីជីថលដែលត្រូវផ្តល់តាមរយៈបណ្តាញអ៊ីនធឺណិត ឬតាមរយៈថ្នាលសេវារួមរបស់រដ្ឋាភិបាល។

សេវាឌីជីថល មានជាអាទិ៍៖

ក-ប្រព័ន្ធគ្រប់គ្រងដាក់ពាក្យ ចុះបញ្ជី របាយការណ៍ តាមដាន បន្តសុពលភាព វាយតម្លៃ និងទូទាត់ប្រាក់។

ខ-សេវាឌីជីថលពីរដ្ឋាភិបាលដើម្បីប្រជាពលរដ្ឋ (G4C)។

គ-សេវាឌីជីថលពីរដ្ឋាភិបាលទៅធុរកិច្ច (G2B)។

ឃ-សេវាឌីជីថលពីរដ្ឋាភិបាលទៅរដ្ឋាភិបាល (G2G)។

ង-សេវាឌីជីថលផ្សេងទៀតដែលអាចផ្តល់តាមរយៈប្រព័ន្ធអ៊ីនធឺណិត មានជាអាទិ៍ សេវាហេដ្ឋារចនាសម្ព័ន្ធឌីជីថលផាស់ (PaaS) ឬ សាស់ (SaaS)។

**មាត្រា១៦ ._ ថ្នាលសេវារួមរដ្ឋាភិបាល**

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំថ្នាលសេវារួមរដ្ឋាភិបាលដែលសម្រួលដល់ការប្រមូលផ្តុំសេវាមួយកន្លែង និងផ្តល់អាក់សេសទៅសេវាឌីជីថលដោយរលូនព្រមទាំងគាំទ្រឱ្យក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធក្នុងការផ្តល់សេវាឌីជីថលរួមគ្នា។

ការរៀបចំ ការគ្រប់គ្រង និងការប្រើប្រាស់ថ្នាលសេវារួមរដ្ឋាភិបាលត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា១៧ ._ ការផ្តល់និងការទទួលបានសេវាឌីជីថល

ក្រសួង ស្ថាប័នដែលផ្តល់សេវាឌីជីថលអាចបំពេញលក្ខខណ្ឌទាំងអស់ ឬណាមួយ ដូចខាងក្រោម៖

ក- រៀបចំសេវាឱ្យទៅជាសេវាឌីជីថល។

ខ- មានទិន្នន័យ ព័ត៌មាន ឬឯកសារពាក់ព័ន្ធនឹងសេវាក្នុងទម្រង់អេឡិចត្រូនិក។

គ- ប្រើប្រាស់ប្រព័ន្ធមួយ ឬប្រព័ន្ធច្រើន។

ឃ- ប្រើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ)បើកចំហ សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ)បិទ សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ)កូនកាត់ ដែលសមស្របទៅតាមកាលៈទេសៈ។

ង- ធានាថាការរៀបចំដំណើរការការងារជួយបង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់សេវាឌីជីថល ។

ច- ប្រើប្រាស់ច្រកផ្តល់សេវាផ្សេងៗ ឯកសារនិងភាសា (ភាសានិយាយនិងភាសាសញ្ញា) និងការណែនាំដែលអាចស្តាប់បាន។

ឆ- សម្រួលដល់ជនមានពិការភាព និងប្រជាពលរដ្ឋដែលខ្វះលទ្ធភាពអាក់សេសទៅសេវាឌីជីថល។

ជ- ធានាថាមានប្រព័ន្ធគាំទ្រគ្រប់គ្រាន់សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ។

ឈ- រក្សានិងជំរុញ សមាហរណកម្ម អន្តរប្រតិបត្តិការ តម្លាភាព និងគណនេយ្យភាពនៃប្រព័ន្ធ។

គោលការណ៍ណែនាំស្តីពីស្តង់ដាលក្ខណៈបច្ចេកទេសនៃការផ្តល់ និងការទទួលបានសេវាឌីជីថលត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា១៨ ._ ក្របខ័ណ្ឌអន្តរប្រតិបត្តិការរដ្ឋាភិបាលឌីជីថលកម្ពុជា

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំក្របខ័ណ្ឌអន្តរប្រតិបត្តិការរដ្ឋាភិបាលឌីជីថលសម្រាប់ដំណើរការ និងការអនុវត្តការងាររបស់រាជរដ្ឋាភិបាល។

ក្របខ័ណ្ឌអន្តរប្រតិបត្តិការរដ្ឋាភិបាលឌីជីថលកម្ពុជាត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា១៩ ._ ការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថល

ពន្ធគ្រប់ប្រភេទ ថ្លៃសេវាសាធារណៈ ថ្លៃសេវាទឹក ថ្លៃសេវាអគ្គិសនី ថ្លៃសេវាសំរាម ប្រាក់ផាកពិន័យ និងការទូទាត់សងប្រាក់សម្រាប់សេវាផ្សេងៗទៀតត្រូវទូទាត់សងតាមប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលដែលកំណត់ដោយរាជរដ្ឋាភិបាល។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ដើម្បីសម្រួលដល់ការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថល។

ការរៀបចំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា២០ ._ ឈ្មោះដែនរដ្ឋាភិបាល

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវគ្រប់គ្រងឈ្មោះដែនរដ្ឋាភិបាល (.gov.kh)។ ក្រសួង ស្ថាប័នត្រូវប្រើប្រាស់ឈ្មោះដែនរដ្ឋាភិបាល។

DRAFT

ការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនរដ្ឋាភិបាល (.gov.kh) ត្រូវអនុលោមតាមអនុក្រឹត្យស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីធឺណិត។

**មាត្រា២១ ._ វេបសាយ និងអ៊ីម៉ែលរដ្ឋាភិបាល**

ក្រសួង ស្ថាប័នត្រូវប្រើឈ្មោះដែនរដ្ឋាភិបាល (.gov.kh) សម្រាប់វេបសាយផ្លូវការរបស់ក្រសួង ស្ថាប័ន។

ឈ្មោះដែនរដ្ឋាភិបាល (.gov.kh)ត្រូវផ្តល់ជូនក្រសួង ស្ថាប័នដោយឥតគិតថ្លៃ។ ក្រសួង ស្ថាប័នត្រូវបង្កើតវេបសាយដោយខ្លួនឯង ឬ ប្រើប្រាស់ទម្រង់វេបសាយដែលបង្កើតដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ក្រសួង ស្ថាប័នត្រូវប្រើអ៊ីម៉ែលតាមឈ្មោះដែនរដ្ឋាភិបាល (.gov.kh) សម្រាប់អ៊ីម៉ែលផ្លូវការរបស់ក្រសួង ស្ថាប័ន។

បុគ្គលដែលមិនប្រើវេបសាយ និងអ៊ីម៉ែលរដ្ឋាភិបាលសម្រាប់ការងារផ្លូវការរបស់ក្រសួង ស្ថាប័នត្រូវផ្តន្ទាទោសតាមមាត្រា៣៨ នៃច្បាប់នេះ។

គោលការណ៍ណែនាំស្តីពីការប្រើប្រាស់វេបសាយនិងអ៊ីម៉ែលរដ្ឋាភិបាលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២២ ._ គណនីបណ្តាញសង្គមក្រសួង ស្ថាប័ន**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវគ្រប់គ្រងបញ្ជីគណនីបណ្តាញសង្គមរបស់ក្រសួង ស្ថាប័ន។

ក្រសួង ស្ថាប័នត្រូវជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អំពីគណនីបណ្តាសង្គមរបស់ក្រសួង ស្ថាប័នដែលប្រើប្រាស់។

មាតិកាដែលផ្សព្វផ្សាយលើបណ្តាញសង្គមផ្លូវការរបស់ក្រសួង ស្ថាប័នត្រូវចាត់ទុកជាព័ត៌មានផ្លូវការរបស់រដ្ឋាភិបាល ហើយត្រូវរក្សាទុកបម្រុងនៅក្នុងនិហិតដ្ឋានទិន្នន័យជាតិ។

បុគ្គលដែលបង្កើតគណនីបណ្តាញសង្គមក្រសួង ស្ថាប័នក្លែងក្លាយ និងផ្សព្វផ្សាយព័ត៌មានក្លែងក្លាយត្រូវផ្តន្ទាទោសតាមមាត្រា៣៩ នៃច្បាប់នេះ។

គោលការណ៍ណែនាំស្តីពីការប្រើប្រាស់គណនីបណ្តាញសង្គមរបស់ក្រសួង ស្ថាប័នត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៣ ._ ដំណើរឆ្ពោះទៅការកាត់បន្ថយការប្រើប្រាស់ក្រដាស**

ក្រសួង ស្ថាប័នត្រូវត្រួតពិនិត្យអំពីការប្រើប្រាស់ក្រដាសបច្ចុប្បន្ន និងរៀបចំផែនការកាត់បន្ថយការប្រើប្រាស់ក្រដាសតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំគោលការណ៍ ស្តង់ដា និងលក្ខខណ្ឌបច្ចេកទេសនៃការកាត់បន្ថយការប្រើប្រាស់ក្រដាស ដោយគិតគូរនូវលក្ខខណ្ឌមួយចំនួន ដូចខាងក្រោម៖

ក- ការប្រើប្រាស់អត្តសញ្ញាណមន្ត្រីរាជការនិងប្រព័ន្ធសុសវែរគ្រប់គ្រងឯកសារ។

ខ- ការដាក់ស្នើឯកសារតាមអេឡិចត្រូនិកសម្រាប់កំណត់ត្រាដែលផ្អែកលើក្រដាស។

គ- ការកាត់បន្ថយការពឹងផ្អែកលើការបោះពុម្ពឯកសារច្រើនពេក។

ឃ- ការប្រើប្រាស់ទម្រង់អេឡិចត្រូនិកនិងអនឡាញ ឬក្លោដរក្សាទុក។

ង- ការកត់ត្រា និងការរាយការណ៍តាមអេឡិចត្រូនិក។

ច- លក្ខខណ្ឌផ្សេងទៀតតាមតម្រូវការរបស់ក្រសួង ស្ថាប័ន។

គោលការណ៍ ស្តង់ដា និងលក្ខខណ្ឌបច្ចេកទេសនៃការកាត់បន្ថយក្រដាសត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៤ ._ ការចូលរួមរបស់ប្រជាពលរដ្ឋតាមប្រព័ន្ធឌីជីថល**

ក្រសួង ស្ថាប័នត្រូវរៀបចំប្រព័ន្ធនៃការផ្តល់មតិកែលម្អរបស់ប្រជាពលរដ្ឋតាមប្រព័ន្ធឌីជីថល និងដោះស្រាយបណ្តឹងតាមប្រព័ន្ធឌីជីថលផងដែរ។

ការរៀបចំប្រព័ន្ធផ្តល់មតិកែលម្អ និងដោះស្រាយបណ្តឹងតាមប្រព័ន្ធឌីជីថលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី៦
## អភិបាលកិច្ចទិន្នន័យ

**មាត្រា២៥ ._ អភិបាលកិច្ចទិន្នន័យ**

ទិន្នន័យរបស់រដ្ឋាភិបាលត្រូវចាត់ទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ។

ទិន្នន័យដែលកំណត់ក្នុងច្បាប់នេះត្រូវចាត់ថ្នាក់ជាទិន្នន័យសម្ងាត់បំផុត ទិន្នន័យសម្ងាត់ និងទិន្នន័យបើកចំហ។

ត្រូវបំពាក់មុខងារបន្ថែមដល់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលឱ្យបំពេញមុខងារដឹកនាំ និងគ្រប់គ្រងទិន្នន័យរដ្ឋាភិបាល។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំគោលការណ៍ណែនាំស្តីពីអភិបាលកិច្ច និងផ្តល់ការត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ មានជាអាទិ៍ និម្មាបនកម្មទិន្នន័យ បញ្ជិកាទិន្នន័យ អន្តរប្រតិបត្តិការនិងការធ្វើសមាហរណកម្មទិន្នន័យ សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) ការប្រើប្រាស់បច្ចេកវិទ្យាក្លោដ និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀតពាក់ព័ន្ធនឹងអភិបាលកិច្ចទិន្នន័យ។

គោលការណ៍ណែនាំស្តីពីអភិបាលកិច្ចទិន្នន័យត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៦ ._ ការប្រមូល រក្សាទុក ផលិតឡើងវិញ ផ្លាស់ប្តូរ ចែកចាយ ឬប្រើប្រាស់ទិន្នន័យ**

ក្រសួង ស្ថាប័នត្រូវប្រមូលនិងរក្សាទុកទិន្នន័យជាទម្រង់អេឡិចត្រូនិកក្នុងឧបករណ៍អេឡិចត្រូនិកណាមួយដែលមានសមត្ថភាពក្នុងការប្រមូល ធ្វើប្រព្រឹត្តកម្ម និងរក្សាទុកដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីការប្រមូលនិងរក្សាទុកទិន្នន័យ។

ការផលិតឡើងវិញ ផ្លាស់ប្តូរ ចែកចាយ ឬប្រើប្រាស់ទិន្នន័យដែលត្រូវបានចាត់ថ្នាក់ជាទិន្នន័យសម្ងាត់បំផុតត្រូវហាមឃាត់។

ការផលិតឡើងវិញ ផ្លាស់ប្តូរ ចែកចាយ ឬប្រើប្រាស់ទិន្នន័យដែលត្រូវបានចាត់ថ្នាក់ជាទិន្នន័យសម្ងាត់ត្រូវមានការអនុញ្ញាតពីគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ឬក្រសួង ស្ថាប័នដែលជាម្ចាស់ទិន្នន័យ។

គោលការណ៍ណែនាំស្តីពីការប្រមូលនិងរក្សាទុកទិន្នន័យត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៧ ._ សមាហរណកម្មប្រព័ន្ធអេឡិចត្រូនិក**

ក្រសួង ស្ថាប័នត្រូវអនុវត្តតាមគោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មប្រព័ន្ធអេឡិចត្រូនិក។

គោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មប្រព័ន្ធអេឡិចត្រូនិកត្រូវកំណត់ ដូចខាងក្រោម៖

ក- ចំណុចពាក់ព័ន្ធនឹងការប្រើប្រាស់សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) ដើម្បីចែករំលែកទិន្នន័យ សម្រាប់ការផ្តល់សេវាសាធារណៈ។

ខ- លក្ខណៈបច្ចេកទេសនៃសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) ត្រូវមានលក្ខខណ្ឌ ដូចខាងក្រោម៖

១-ម៉ាស៊ីនអាចបាន។

២-អាក់សេសជាសាធារណៈ។

៣-ស្ថេរភាពនិងអាចពង្រីកបាន។

៤-អាចរកបានដោយក្រសួងស្ថាប័ន។

៥-អាចបំពេញមុខងារលើថ្នាលផ្សេងៗដោយប្រើប្រាស់ពហុភាសា។

៦-មានសង្គតិភាពជាមួយគោលនយោបាយសន្តិសុខសាយប័ររបស់រដ្ឋាភិបាល។

សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) ដែលប្រើដោយក្រសួង ស្ថាប័នដើម្បីឱ្យមានអាក់សេសទៅទិន្នន័យចំហត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

ក- ត្រូវមានឯកសារត្រឹមត្រូវដែលមានកូដជាគំរូ និងព័ត៌មានគ្រប់គ្រាន់សម្រាប់អ្នកអភិវឌ្ឍសុសវែរយកទៅប្រើប្រាស់។

ខ- ត្រូវមានវដ្តនៃការអភិវឌ្ឍសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) សម្រាប់ក្រសួង ស្ថាប័នដែលជាម្ចាស់។

គ- ត្រូវធានាថាសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) អាចប្រើប្រាស់បានយ៉ាងហោចណាស់បីជំនាន់។

ឃ- ត្រូវមានយន្តការផ្ទៀតផ្ទាត់ការប្រើប្រាស់សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) ដល់ក្រសួង ស្ថាប័នដើម្បីអាចធ្វើអន្តរប្រតិបត្តិការសេវាជាមួយប្រព័ន្ធឯកគណនី (អេសអេសអូ)។

ង- ជំរុញភាពងាយស្រួលនិងតម្លាភាពនៃសមាហរណកម្មនិងអន្តរប្រតិបត្តិការនៃទិន្នន័យ។

ច- ជំរុញសុវត្ថិភាពនិងភាពទុកចិត្តបាននៃការចែករំលែកទិន្នន័យនិងព័ត៌មានដើម្បីផ្តល់សេវាសាធារណៈឌីជីថល។

ឆ- លើកទឹកចិត្តនិងបង្កើតនវានុវត្តន៍។

ជ- ជំរុញស្តង់ដាបើកចំហនៃអន្តរប្រតិបត្តិការសុសវែរក្នុងក្រសួង ស្ថាប័ន។

ឈ- ធានាភាពងាយស្រួលក្នុងការអាក់សេសព័ត៌មានដែលបានប្រមូលដោយក្រសួង ស្ថាប័ន។

ញ- អនុលោមតាមគោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មប្រព័ន្ធអេឡិចត្រូនិក។

ក្រសួង ស្ថាប័នដែលប្រើប្រាស់ប្រព័ន្ធមួយឬច្រើនត្រូវផ្តល់ឱ្យគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលនូវសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) ដែលប្រើប្រាស់ដោយអង្គភាពខ្លួនសម្រាប់ផ្តល់សេវាឌីជីថល។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវបង្កើតបញ្ជិកាសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) ដែលប្រើប្រាស់ដោយក្រសួង ស្ថាប័ន។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវកំណត់ស្តង់ដាសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) សម្រាប់កម្រិតហេដ្ឋារចនាសម្ព័ន្ធឌីជីថលផ្សេងៗ កម្រិតកម្មវិធី កម្រិតបណ្តាញ និងកម្រិតសេវូបករណ៍ ដើម្បីគ្រប់គ្រងវំហូរនៃទិន្នន័យរបស់រដ្ឋាភិបាល។

DRAFT

គោលការណ៍ណែនាំស្តីពីស្តង់ដាសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) សម្រាប់កម្រិតហេដ្ឋារចនាសម្ព័ន្ធឌីជីថល កម្រិតកម្មវិធី កម្រិតបណ្តាញ និងកម្រិតសេវូបករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា២៨ ._ ការចែករំលែកទិន្នន័យ

ក្រសួង ស្ថាប័នត្រូវអនុវត្តតាមស្តង់ដា និងលក្ខណៈបច្ចេកទេសនៃការចែករំលែកទិន្នន័យ។

នៅពេលចែករំលែកទិន្នន័យ ក្រសួង ស្ថាប័នត្រូវមានការប្រុងប្រយ័ត្នដើម្បីធានាថាការចែករំលែកទិន្នន័យត្រូវបានធ្វើឡើងក្នុងទម្រង់ដែលធានាសន្តិសុខ ដោយគ្មានការបំពានទៅលើទិន្នន័យឯកជន ឬគ្មានចំណុចខ្សោយក្នុងការចូលលួចទិន្នន័យ។

គោលការណ៍ណែនាំស្តីពីការចែករំលែកទិន្នន័យត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា២៩ ._ ការអាក់សេសទិន្នន័យ

ក្រសួង ស្ថាប័នត្រូវគ្រប់គ្រងការអាក់សេសទិន្នន័យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

បុគ្គលមិនត្រូវអាក់សេសទិន្នន័យដែលរក្សាទុកដោយក្រសួង ស្ថាប័នឡើយ លើកលែងតែមានការអនុញ្ញាតពីក្រសួង ស្ថាប័ននោះ។

ក្នុងករណីអាក់សេសទៅទិន្នន័យបុគ្គលដែលរក្សាទុកដោយមធ្យោបាយអេឡិចត្រូនិករបស់ក្រសួង ស្ថាប័នត្រូវមានការអនុញ្ញាតក្រសួង ស្ថាប័ន និងការយល់ព្រមពីប្រធានទិន្នន័យ។

បុគ្គលដែលមានបំណងអាក់សេសទិន្នន័យត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅក្រសួង ស្ថាប័ន។

ក្រសួង ស្ថាប័នត្រូវផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរ និងបញ្ជាក់អំពី ហេតុផល ប្រភេទ ថេរវេលា និងលក្ខខណ្ឌផ្សេងទៀតនៃការអនុញ្ញាតឱ្យអាក់សេសទិន្នន័យ។

បទប្បញ្ញត្តិនៃមាត្រានេះមិនហាមឃាត់ ឬដាក់កម្រិតសិទ្ធិបុគ្គលក្នុងការអាក់សេសទៅទិន្នន័យបុគ្គលដែលរក្សាទុកដោយក្រសួង ស្ថាប័នឡើយ។

គោលការណ៍ណែនាំស្តីពីការស្នើសុំអាក់សេសទិន្នន័យត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា៣០ ._ ទិន្នន័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រសួង ស្ថាប័នដែលធ្វើប្រតិភូកម្មសេវាសាធារណៈថ្នាក់ក្រោមជាតិត្រូវសហការរៀបចំវិធានការសមស្របពាក់ព័ន្ធនឹងការបង្កើត ការប្រមូល ការធ្វើប្រព្រឹត្តកម្ម ការរក្សាទុក ការធានាសន្តិសុខ ការប្រើប្រាស់ និងការចែករំលែកទិន្នន័យ។

ការគ្រប់គ្រង និងការប្រើប្រាស់ទិន្ន័យនៅថ្នាក់ក្រោមជាតិត្រូវអនុលោមតាមគោលការណ៍ណែនាំស្តីពីអភិបាលកិច្ចទិន្នន័យដែលកំណត់ដោយអនុក្រឹត្យ។

DRAFT

# ជំពូកទី៧
# គម្រោង ថវិកា និងមូលនិធិរដ្ឋាភិបាលឌីជីថល

## មាត្រា៣១ ._ គម្រោងរដ្ឋាភិបាលឌីជីថល

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំផែនការនិងទិសដៅសម្រាប់អនុវត្តគម្រោងរដ្ឋាភិបាលឌីជីថល និងស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ ក្រសួង ស្ថាប័នត្រូវចូលរួមរៀបចំគម្រោងរដ្ឋាភិបាលឌីជីថលស្របតាមផែនការនិងទិសដៅនៃរដ្ឋាភិបាលឌីជីថល។

គម្រោងរដ្ឋាភិបាលឌីជីថលត្រូវកំណត់អាទិភាពគម្រោងរយៈពេលខ្លី មធ្យម និងវែង។ គម្រោងរដ្ឋាភិបាលឌីជីថលត្រូវអនុវត្តតាមឯកសារណែនាំលើពិធីសារ លក្ខណៈបច្ចេកទេស អន្តរប្រតិបត្តិការ សន្តិសុខសាយប័រ និងរូបរាងការរចនាផតថល ជាអាទិ៍ ដើម្បីធានាសង្គតិភាពនៃទិន្នន័យអន្តរប្រតិបត្តិការរវាងប្រព័ន្ធ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវកំណត់ និងបែងចែកថវិកាជាតិសម្រាប់គម្រោងរដ្ឋាភិបាលឌីជីថលដែលបានទទួលការឯកភាពពីរាជរដ្ឋាភិបាល។ ក្រៅពីថវិកាជាតិ ក្រសួង ស្ថាប័នអាចគៀគរប្រភពធនធានស្របច្បាប់ដើម្បីអនុវត្តគម្រោង តាមរយៈដៃគូអភិវឌ្ឍន៍ ឬជាការវិនិយោគ។

ការគ្រប់គ្រង និងការអនុវត្តគម្រោងរដ្ឋាភិបាលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## មាត្រា៣២ ._ មូលនិធិរដ្ឋាភិបាលឌីជីថល

មូលនិធិរដ្ឋាភិបាលឌីជីថលត្រូវបានបង្កើតឡើងសម្រាប់ប្រតិបត្តិការគម្រោងរដ្ឋាភិបាលឌីជីថល។

ប្រភពនៃមូលនិធិរដ្ឋាភិបាលឌីជីថលត្រូវមានប្រភពចេញពីថវិកាជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ និងប្រភពស្របច្បាប់ផ្សេងទៀត។

ការគ្រប់គ្រង និងការប្រើប្រាស់មូលនិធិរដ្ឋាភិបាលឌីជីថលត្រូវកំណត់ដោយអនុក្រឹត្យ។

# ជំពូកទី៨
# កិច្ចសហប្រតិបត្តិការ និងសន្ទស្សន៍នៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល

## មាត្រា៣៣ ._ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍និងវិស័យឯកជន

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងភាគីពាក់ព័ន្ធ ក្នុងការអភិវឌ្ឍជំនាញឌីជីថល ដើម្បីជំរុញការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលនៅកម្ពុជាស្របតាមនិន្នាការ និងការវិវត្តន៍ជាអន្តរជាតិ។

## មាត្រា៣៤ ._ សន្ទស្សន៍នៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំការស្ទង់មតិអំពីការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជានៅរៀងរាល់ ២ (ពីរ) ឆ្នាំម្តង។

ការកសាងរដ្ឋាភិបាលឌីជីថលត្រូវរួមបញ្ចូលអំពីតួនាទីបញ្ញាសិប្បនិម្មិតផងដែរ ដើម្បីឱ្យស្របនឹងក្របខ័ណ្ឌការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលក្នុងយុគសម័យបញ្ញាសិប្បនិម្មិត។

គោលការណ៍ណែនាំស្តីពីការប្រើប្រាស់បញ្ញាសិប្បនិម្មិតសម្រាប់រដ្ឋាភិបាលឌីជីថលត្រូវកំណត់ដោយអនុក្រឹត្យ។



DRAFT

### មាត្រា៣៥ ._ ទិវារដ្ឋាភិបាលឌីជីថល

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំវេទិការដ្ឋាភិបាលឌីជីថលយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីការលើកកម្ពស់ ប្រតិបត្តិការ និងការយល់ដឹងអំពីរដ្ឋាភិបាលឌីជីថលក៏ដូចជាការផ្តល់សេវាសាធារណៈ។

## ជំពូកទី៩
## ការអនុវត្ត

### មាត្រា៣៦ ._

បន្ទាប់ពីច្បាប់នេះចូលជាធរមាន រាជរដ្ឋាភិបាលត្រូវចេញអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះឱ្យមានប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ។

## ជំពូកទី១០
## ទោសប្បញ្ញត្តិ

### មាត្រា៣៧ ._ ទណ្ឌកម្ម

បុគ្គលដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្ម ដូចមានចែងក្នុងជំពូកទី១០ នៃច្បាប់នេះ ដោយពុំទាន់គិតដល់ទណ្ឌកម្មវិន័យរដ្ឋបាលសម្រាប់មន្ត្រីរាជការ និងទោសព្រហ្មទណ្ឌផ្សេងទៀត។

### មាត្រា៣៨ ._ បទល្មើសនៃការមិនប្រើប្រាស់អ៊ីម៉ែលឬវេបសាយរដ្ឋាភិបាល

ត្រូវផាកពិន័យជាប្រាក់មិនលើសពី ២០០ ០០០ (ពីររយពាន់) រៀល ចំពោះរូបវន្តបុគ្គលម្នាក់ៗដែលបំពានកថាខណ្ឌទី៤ នៃមាត្រា២១ នៃច្បាប់នេះ។

### មាត្រា៣៩ ._ បទល្មើសបង្កើតគណនីបណ្តាញសង្គមក្រសួង ស្ថាប័នឬព័ត៌មានក្លែងក្លាយ

ត្រូវផាកពិន័យជាប្រាក់ចំពោះបុគ្គលដែលបំពានបទប្បញ្ញត្តិនៃមាត្រា២២ នៃច្បាប់នេះ ដូចខាងក្រោម៖

- មិនលើសពី ១០ ០០០ ០០០ (ដប់លាន) រៀល ចំពោះរូបវន្តបុគ្គលម្នាក់ៗដែលជាប់ពាក់ព័ន្ធ
- មិនលើសពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះនីតិបុគ្គលនីមួយៗដែលជាប់ពាក់ព័ន្ធ។

### មាត្រា៤០ ._ បទល្មើសនៃការផលិតឡើងវិញទិន្នន័យដោយគ្មានការអនុញ្ញាត

ត្រូវផាកពិន័យជាប្រាក់ចំពោះបុគ្គលដែលបំពានបទប្បញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា២៦ នៃច្បាប់នេះ ដូចខាងក្រោម៖

- ចំពោះរូបវន្តបុគ្គលម្នាក់ៗដែលជាប់ពាក់ព័ន្ធ៖
  - មិនលើសពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល សម្រាប់ទិន្នន័យសម្ងាត់បំផុត
  - មិនលើសពី ១០ ០០០ ០០០ (ដប់លាន) រៀល សម្រាប់ទិន្នន័យសម្ងាត់។
- ចំពោះនីតិបុគ្គលនីមួយៗដែលជាប់ពាក់ព័ន្ធ៖
  - មិនលើសពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល សម្រាប់ទិន្នន័យសម្ងាត់បំផុត
  - មិនលើសពី ១០០ ០០០ ០០០ (មួយរយលាន) រៀល សម្រាប់ទិន្នន័យសម្ងាត់។

### មាត្រា៤១ ._ បទល្មើសមិនបង់ប្រាក់ផាកពិន័យ

បុគ្គលដែលត្រូវបានផាកពិន័យជាប្រាក់ ហើយមិនបានបង់ប្រាក់ផាកពិន័យក្នុងរយៈពេលលើសពី៖

ក- ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតបង្គាប់ឱ្យបង់ប្រាក់ផាកពិន័យ ត្រូវទទួលការផាកពិន័យជាប្រាក់ពីរដងនៃចំនួនទឹកប្រាក់ផាកពិន័យ ដែលមិនទាន់បានបង់។

DRAFT

ខ-៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតបង្គាប់ឱ្យបង់ប្រាក់ផាកពិន័យ ត្រូវទទួលការផាកពិន័យជាប្រាក់បីដងនៃចំនួនទឹកប្រាក់ផាកពិន័យ ដែលមិនទាន់បានបង់។

គ-៩០ (កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតបង្គាប់ឱ្យបង់ប្រាក់ផាកពិន័យ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច ដើម្បីចាត់ការតាមនីតិវិធី។

**មាត្រា៤២ ._ ការទទួលខុសត្រូវព្រហ្មទណ្ឌ**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

រូបវន្តបុគ្គលដែលនៅតែប្រព្រឹត្តល្មើសដដែល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ថ្ងៃ ទៅ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់មិនលើសពី ១០ ០០០ ០០០ (ដប់លាន) រៀល។

នីតិបុគ្គលដែលនៅតែប្រព្រឹត្តបទល្មើសដដែល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៤៣ ._**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន ត្រូវបន្តមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៤៤ ._ និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា៤៥ ._**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.............ខែ...........ឆ្នាំ២០២....
នាសម័យប្រជុំរដ្ឋសភាលើកទី..........នីតិកាលទី៧។
ថ្ងៃ..................ខែ.........ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦...
រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២....

**ប្រធានរដ្ឋសភា**

DRAFT

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថលនៃព្រះរាជាណាចក្រកម្ពុជា
## សទ្ទានុក្រម

| | | |
|---|---|---|
| ១ | **ក្រសួង ស្ថាប័ន**<br>Ministries/institutions | សំដៅដល់ក្រសួង រដ្ឋលេខាធិការដ្ឋាន គណៈកម្មាធិការ ក្រុមប្រឹក្សា អាជ្ញាធរ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលត្រូវបានបង្កើតដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។ |
| ២ | **គណនីផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថល**<br>Verified digital ID account | សំដៅដល់គណនីឌីជីថលដែលកំណត់អត្តសញ្ញាណរូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងពិភពឌីជីថល។ |
| ៣ | **ដែនរដ្ឋាភិបាល .gov.kh**<br>Government Domain | សំដៅដល់ដែនជាតិកម្រិតទី២ ដែលប្រើប្រាស់សម្រាប់ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងស្ថានតំណាងព្រះរាជាណាចក្រកម្ពុជានៅបរទេសផងដែរ។ |
| ៤ | **ថ្នាលផ្លាស់ប្តូរទិន្នន័យធំ**<br>Bulky data exchange platform | សំដៅដល់ថ្នាលឌីជីថលរដ្ឋាភិបាលដែលប្រើប្រាស់សម្រាប់ផ្លាស់ប្តូរទិន្នន័យជាកញ្ចប់ដែលមានទំហំធំ ( bulky data ) ឬទិន្នន័យធំ ( big data )។ |
| ៥ | **ថ្នាលសេវារួមរដ្ឋាភិបាល**<br>Government's common systems | សំដៅដល់ថ្នាល់ឌីជីថលរបស់រដ្ឋាភិបាលដែលត្រូវបានអភិវឌ្ឍនិងដំណើរការហើយអាចតភ្ជាប់និងចែករំលែកការប្រើប្រាស់ដល់ក្រសួង ស្ថាប័ន។ |
| ៦ | **ទិន្នន័យរបស់រដ្ឋាភិបាល**<br>Government data | សំដៅដល់បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬ កម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យ ឬប្រព័ន្ធ អេឡិចត្រូនិក របស់ក្រសួង ស្ថាប័ននៅក្នុងអង្គនីតិប្រតិបត្តិ។ |
| ៧ | **ទិន្នន័យសម្ងាត់បំផុត**<br>Top-secret data | សំដៅដល់ទិន្នន័យដែលមានហានិភ័យខ្ពស់ចំពោះរដ្ឋាភិបាល ក្នុងករណីដែលទិន្នន័យត្រូវបានប្រើប្រាស់ លាតត្រដាង កែប្រែ ឬបំផ្លាញចោលដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាល ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច។ ឧទាហរណ៍៖ ទិន្នន័យពាក់ព័ន្ធនឹងសន្តិសុខជាតិ ការសម្ងាត់ជាតិ ឬទិន្នន័យសម្ងាត់បំផុតផ្សេងទៀតដែលកំណត់ដោយច្បាប់។ |

DRAFT

| | | |
|---|---|---|
| ៨ | **ទិន្នន័យសម្ងាត់**<br>Confidential data | សំដៅដល់ទិន្នន័យដែលមានហានិភ័យមធ្យមចំពោះរដ្ឋាភិបាល ក្នុងករណីដែលទិន្នន័យត្រូវបានប្រើប្រាស់ លាតត្រដាង កែប្រែ ឬបំផ្លាញចោលដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាល ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច។ ឧទាហរណ៍៖ ទិន្នន័យពាក់ព័ន្ធនឹងកិច្ចការផ្ទៃក្នុងរបស់រដ្ឋាភិបាល ក្រសួង ស្ថាប័ន ឬទិន្នន័យសម្ងាត់ផ្សេងទៀតដែលកំណត់ដោយច្បាប់។ |
| ៩ | **ទិន្នន័យបើកចំហ**<br>Open data | សំដៅដល់ទិន្នន័យដែលមានហានិភ័យទាប ឬគ្មានហានិភ័យចំពោះរដ្ឋាភិបាល ក្នុងករណីដែលទិន្នន័យត្រូវបានប្រើប្រាស់ លាតត្រដាង កែប្រែ ឬបំផ្លាញចោលដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាល ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច។ ឧទាហរណ៍៖ ទិន្នន័យថវិកាជាតិ ទិន្នន័យលទ្ធកម្ម ឬ ទិន្នន័យបើកចំហផ្សេងទៀតដែលកំណត់ដោយច្បាប់។ |
| ១០ | **ទិន្នន័យជាកញ្ចប់ដែលមានទំហំធំ**<br>Bulky data | សំដៅដល់ទិន្នន័យដែលមានឯកសារទំហំធំ (large file size) ដែលពិបាកក្នុងការផ្លាស់ប្តូរ ឬ រក្សាទុក ដូចជា ឯកសាររូបភាពវេជ្ជសាស្ត្រ (Medical image files) ឯកសារខ្សែភាពយន្តដើមមិនទាន់បានកាត់ត (Raw video footage) រូបភាពផ្កាយរណប (satellite images)។ |
| ១១ | **ទិន្នន័យធំ**<br>Big data | សំដៅដល់ សំណុំទិន្នន័យដែលមានបរិមាណច្រើនសន្ធឹកសន្ធាប់ ច្រើនប្រភព ច្រើនប្រភេទ និងមានកំណើនកើនឡើង យ៉ាងឆាប់រហ័ស ដែលតម្រូវឱ្យមានវិធីសាស្ត្រនិង បច្ចេកវិទ្យាពិសេសសម្រាប់គ្រប់គ្រងនិងវិភាគលើ ទិន្នន័យទាំងនោះ សម្រាប់ជាជំនួយដល់ការសម្រេចចិត្ត និងបម្រើផលប្រយោជន៍ផ្សេងៗទៀត។ ឧទាហរណ៍ ទិន្ន័យលើបណ្តាញសង្គម (Social media feeds) ទិន្នន័យពីឧបករណ៍អាយអូធី (IoT sensor data)។ |
| ១២ | និហិតដ្ឋានទិន្នន័យជាតិ<br>National data repository | សំដៅដល់កន្លែងឬឃ្លាំងផ្ទុកទិន្នន័យបម្រុងទិន្នន័យជាតិ ឬ ទិន្នន័យរដ្ឋាភិបាល និង/ឬទិន្នន័យក្រសួង ស្ថាប័ន ដែលមានស្តង់ដានិងសុវត្ថិភាពខ្ពស់ដើម្បីបង្ការការបាត់បង់ទិន្នន័យដោយហេតុការណ៍ណាដែលមិនបានគ្រោងទុក។ |
| ១៣ | **បច្ចេកវិទ្យាក្លោដ**<br>Cloud technology | សំដៅដល់បច្ចេកវិទ្យាដែលផ្តល់លទ្ធភាពដល់ការប្រើប្រាស់ និង ចែករំលែកធនធានគណនា ធនធានបណ្តាញ ធនធានសម្រាប់ផ្ទុកទិន្នន័យ ធនធានសុសវែរ និង ថ្នាលអភិវឌ្ឍសុសវែរ តាមប្រព័ន្ធអ៊ីនធឺ |

DRAFT

| | | |
|---|---|---|
| | | ណិតប្រកប ដោយប្រសិទ្ធភាពស្របទៅតាមតម្រូវការ ដោយអ្នក ប្រើប្រាស់មិនចាំបាច់គ្រប់គ្រងធនធានទាំងនេះ ដោយផ្ទាល់។ |
| ១៤ | **បច្ចេកវិទ្យាឌីជីថល**<br>Digital technology | សំដៅដល់បច្ចេកវិទ្យាដែលប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ឧបករណ៍ឆ្លាត ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ធនធាន គណនា សម្រាប់បង្កើត ផ្ទុក បំប្លែង និង វិភាគទិន្នន័យ។ |
| ១៥ | **បណ្តាញហេដ្ឋារចនាសម្ព័ន្ធដោយឡែករដ្ឋាភិបាល**<br>Government private network | សំដៅដល់បណ្តាញកុំព្យូទ័រ ដែលត្រូវបានរៀបចំដាច់ដោយ ឡែកពីបណ្តាញអ៊ីនធឺណិត សម្រាប់តភ្ជាប់ផ្ទៃក្នុង ក្រសួងស្ថាប័ន ដើម្បីធានាសុវត្ថិភាពនិងបង្កើន ប្រសិទ្ធភាពប្រព័ន្ធរដ្ឋាភិបាលឌីជីថល។ |
| ១៦ | **បញ្ជិកាទិន្នន័យ**<br>Data registry | សំដៅដល់ប្រព័ន្ធឌីជីថលកណ្តាលដែលប្រើប្រាស់ដើម្បីប្រមូល រក្សាទុក គ្រប់គ្រង និងទាញយកទិន្នន័យដែលត្រូវបានរៀបចំតាមវិស័យ ដូចជា ទិន្នន័យទូរគមនាគមន៍ ទិន្នន័យសុខភាព ទិន្នន័យហិរញ្ញវត្ថុ ....។ |
| ១៧ | **បញ្ញាសិប្បនិម្មិត**<br>Artificial intelligence | សំដៅដល់ជ្រុងមួយនៃវិទ្យាសាស្ត្រកុំព្យូទ័រផ្តោតលើការបង្កើត សុសវែរ កម្មវិធី ឬឧបករណ៍ ដែលមានសមត្ថភាព អាចធ្វើការសម្រេចចិត្ត ដោយខ្លួនឯងបាន ឬធ្វើ សកម្មភាពជំនួសមនុស្សបាន។ |
| ១៨ | **មជ្ឈមណ្ឌលទិន្នន័យ**<br>Data center | សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវាកម្ម ផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ |
| ១៩ | **រដ្ឋាភិបាលឌីជីថល**<br>Digital government | សំដៅដល់ដំណើរការនៃការធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាល និង សេវាសាធារណៈតាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យា ឌីជីថល ដូចជាកុំព្យូទ័រ ឧបករណ៍ឆ្លាត និង ប្រព័ន្ធអ៊ីនធឺណិត សំដៅជួយសម្រួលដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋ ការសម្រេចចិត្ត និង ការផ្តល់សេវាជូនប្រជាពលរដ្ឋ វិស័យ ឯកជន និង ស្ថាប័នពាក់ព័ន្ធនានា ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និង បរិយាបន្នកម្ម ។ |
| ២០ | **សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ)**<br>Application Programming Interface (API) | សំដៅដល់ច្រកចេញ-ចូលនៃទំនាក់ទំនងក្នុងការផ្លាស់ប្តូរទិន្នន័យ រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីរ ឬ ច្រើន ។ |
| ២១ | **សេវាឌីជីថល**<br>Digital services | សំដៅដល់សេវាដំណើរការដោយអ៊ីនធឺណិតដែលផ្តល់និងអាក់សេស តាមរយៈហេដ្ឋារចនាសម្ព័ន្ធឌីជីថល។ |

DRAFT

| | | |
|---|---|---|
| ២២ | **សេវាហេដ្ឋារចនាសម្ព័ន្ធផាស់**<br>Platform as a service<br>(PaaS) | សំដៅដល់ថ្នាលដែលផ្តល់ឧបករណ៍និងសេវាកម្មដល់អ្នកអភិវឌ្ឍ ដើម្បីអភិវឌ្ឍ សាកល្បង និងដាក់ឱ្យប្រើប្រាស់កម្មវិធី។ ឧទាហរណ៍ សម្រាប់ការអភិវឌ្ឍវេបសាយ (Google App Engine, Microsoft Azure App Services...) សម្រាប់ការគ្រប់គ្រងសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ អេភីអាយ (AWS API Gateway....) សម្រាប់ថ្នាលសម្រាប់ការរៀនដោយម៉ាស៊ីន (Google AI Platform...) |
| ២៣ | **សេវាហេដ្ឋារចនាសម្ព័ន្ធសាស់**<br>Software as a service<br>(SaaS) | សំដៅដល់កម្មវិធីសុសវែរពេញលេញដែលផ្តល់តាមរយៈអ៊ីនធឺណិត ឱ្យអ្នកប្រើប្រាស់ចុងក្រោយ។ ឧទាហរណ៍ សម្រាប់អ៊ីម៉ែល (Gmail, Microsoft Outlook...) សម្រាប់ការផ្ទុកឯកសារ (Dropbox, Google Drive...) |
| ២៤ | **ហេដ្ឋារចនាសម្ព័ន្ធឌីជីថល**<br>Digital infrastructure | សំដៅដល់ឧបករណ៍ ឬយន្តការដែលប្រើប្រាស់ឬអាចបញ្ជូនទិន្នន័យ និងផ្តល់សេវា និងអាចជាខ្សែ ឬ និម្មិត ឬហាដវែរ ឬ សុសវែរដែលមានជាអាទិ៍<br>- បណ្តាញហេដ្ឋារចនាសម្ព័ន្ធដោយឡែករដ្ឋាភិបាល (Government Private Network)<br>- មជ្ឈមណ្ឌលទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាល<br>- ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល<br>- និហិតដ្ឋានទិន្នន័យជាតិ<br>- ថ្នាលផ្លាស់ប្តូរទិន្នន័យធំ<br>- ហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់<br>- ថ្នាលសេវារួមរដ្ឋាភិបាល<br>- ប្រព័ន្ធ<br>- កម្មវិធីសុសវែរ<br>- ប្រព័ន្ធសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ)និងសមាហរណកម្ម<br>- ឧបករណ៍ភ្ជាប់ចុងក្រោយ<br>- ចំណុចតភ្ជាប់អ៊ីនធឺណិត<br>- សេវូបករណ៍ ឧបករណ៍ចង្អុលផ្លូវ និងម៉ូដឹម<br>- ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ |

DRAFT

| | | |
|---|---|---|
| ២៥ | **ហេដ្ឋារចនាសម្ព័ន្ធក្លោដជួលប្រើដោយរដ្ឋាភិបាល**<br>Government leased cloud infrastructure | សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធក្លោដដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនលក់សេវាក្លោដ (cloud service vendor) ហើយត្រូវបានជួលសម្រាប់ប្រើប្រាស់ដោយរដ្ឋាភិបាល។ |
| ២៦ | **ហេដ្ឋារចនាសម្ព័ន្ធក្លោដដោយឡែករបស់រដ្ឋាភិបាល**<br>Government private cloud infrastructure | សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធក្លោដដែលជាកម្មសិទ្ធិរបស់រដ្ឋាភិបាល។ |
| ២៧ | **ហេដ្ឋារចនាសម្ព័ន្ធក្លោដរដ្ឋាភិបាល**<br>Government cloud infrastructure | សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធក្លោដជួលប្រើដោយរដ្ឋាភិបាល (Government Leased Cloud Infrastructure) និងហេដ្ឋារចនាសម្ព័ន្ធក្លោដដោយឡែករបស់រដ្ឋាភិបាល (Government Private Cloud Infrastructure)។ |
| ២៨ | **ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល**<br>Digital ID infrastructure | សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់កំណត់អត្តសញ្ញាណបុគ្គលឬវត្ថុ ដែលអាចជារូបវន្តបុគ្គល នីតិបុគ្គល កម្មវិធី ឬឧបករណ៍ផ្សេងៗ។ អត្តសញ្ញាណឌីជីថលអនុញ្ញាតឱ្យ មានស្វ័យប្រវត្តិកម្មនៃការវាយតម្លៃ និងការផ្ទៀងផ្ទាត់ អត្តសញ្ញាណអ្នកប្រើប្រាស់ ដែលធ្វើអន្តរកម្មជាមួយ ប្រព័ន្ធឌីជីថល ដោយមិនចាំបាច់មានការផ្ទៀងផ្ទាត់ផ្ទាល់ពីមនុស្ស។ |
| ២៩ | **ហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់**<br>Payment gateway infrastructure | សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់បម្រើដល់ការទូទាត់សងប្រាក់លើសេវា សាធារណៈ ការប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែន សារពើពន្ធ ព្រមទាំងធុរកិច្ចឌីជីថលនានា។ |
| ៣០ | **អន្តរប្រតិបត្តិការ**<br>Interoperability | សំដៅដល់សមត្ថភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអាចធ្វើសន្ទានកម្មជាមួយគ្នាក្នុងការផ្លាស់ប្តូរ និង ការប្រើប្រាស់ទិន្នន័យដែលជាទូទៅ កើតឡើងដោយស្វ័យប្រវត្តិក្រោមលក្ខខណ្ឌច្បាស់លាស់។ |

DRAFT